DAY 02: MASS DEMO TO PROTECT KHMER HISTORY AND THE NATIONAL HONOR OF CAMBODIA IN PHNOM PENH (OCT 05)

សហគមន៍ខ្មែរកម្ពុជាក្រោម និង សម្ព័ន្ធយុវជនខ្មែរ ដើម្បីប្រជាធិបតេយ្យ សូមលំឱនកាយ អំពាវនាវព្រះករុណាព្រះគុណម្ចាស់គ្រប់ព្រះអង្គ បងប្អូនរួមឈាមទាំងអស់ ព្រះមេត្តា និង មេត្តារួបរួមសាមគ្គីគ្នាជាធ្លុងមួយ ដោយមិនប្រកាន់និន្នាការនយោបាយឬសាសនា ឈប់ប្រើប្រាស់ទំនិញយួន និងសេវាកម្ម ផ្សេងៗរបស់យួនចាប់ពីពេលនេះតទៅ។

KKC and KYAD (The Khmer Kampuchea Krom Community and Khmer Youth Alliance for Democracy) appeal to you, the Buddhist monks and compatriots to boycott the Vietnamese products and services, to stop buying, stop using Vietnam's products and services to show national solidarity and to help uplift the Cambodian economy and products and services in return and Cambodia can become self-sufficient.

To learn more about Kampuchea Krom and her people's continued struggle, please log onto KKC website: http://khmerkromngo.org.

Photos courtesy Willaim Guang, Reaksmey Chea, Ngin Peouv, Neakporn KonKhmer, Vichet Meas, Srey Mech, ស្រីណុចកូនខ្មែរ, Khmer Sovannaphom, Thyda Hang, Chum Hout, Anna Anna Lekacnrf




ការពារ
តំបន់អារ៉ែង


belonging to
Vietnam remain continue their ambition to






ខ្មែររួមគ្នាសាមគ្គី ខ្មែររស់ ខ្មែរបែកបាក់ ខ្មែរស្លាប់ ជយោ! ខ្មែរកម្ពុជាក្រោម




























BROWN


KHMER KAMPUCHEA KROM COMMUNITY


does not recognize Kampuchea Krom as belonging to Khmer






DP-A3
83.4






Canon








10.05.2014 03:45PM



# សហគមន៍ខ្មែរកម្ពុជាក្រោម

**THE KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

លេខ: ០៧២/១៤ ស.ខ.ក.ក.

# សេចក្តីអំពាវនាវ

ដើម្បីឆ្លើយតបនឹងការមើលងាយប្រជាជាតិខ្មែរ និងការបំភ្លៃប្រវត្តិសាស្ត្រខ្មែរដោយចេតនារបស់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម យើងខ្ញុំព្រះករុណា យើងខ្ញុំ សូមលំឱនកាយអំពាវនាវព្រះករុណាព្រះគុណម្ចាស់គ្រប់ព្រះអង្គ បងប្អូនរួមឈាមទាំងអស់ ព្រះមេត្តានិងមេត្តារួបរួមសាមគ្គីគ្នាជាធ្លុងមួយ ដោយមិនប្រកាន់និន្នាការនយោបាយឬសាសនា ឈប់ប្រើប្រាស់ទំនិញយួន និងសេវាកម្មផ្សេងៗរបស់យួនចាប់ពីពេលនេះតទៅ។

ការសាមគ្គីគ្នាដោយមិនប្រើប្រាស់ទំនិញ និងសេវាកម្មផ្សេងៗរបស់យួន គឺជាការឆ្លើយតបដោយសេចក្តីថ្លៃថ្នូរនៃប្រជាជាតិខ្មែរចំពោះអាកប្បកិរិយាដ៏គឃ្លើននៃរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលបានមើលងាយប្រជារាស្ត្រខ្មែរ និងបំភ្លៃប្រវត្តិសាស្ត្រខ្មែរដោយឥតអៀនខ្មាស់។

ការរួបរួមសាមគ្គីគ្នានៃប្រជាជាតិខ្មែរធ្វើពហិការមិនប្រើប្រាស់ទំនិញនិងសេវាកម្មផ្សេងៗរបស់យួននាពេលនេះ គឺជាសារមួយប្រាប់រដ្ឋាភិបាលវៀតណាមឲ្យបញ្ឈប់ការតាំងខ្លួនជាចៅហ្វាយនាយមកលើកម្ពុជា ជាបន្តទៀត។ ព្រោះពេលនេះ ប្រជារាស្ត្រខ្មែរត្រូវការរស់នៅដោយសុខសន្តិភាព ឯករាជ្យម្ចាស់ការ និង ទំនាក់ទំនងល្អជាមួយប្រទេសជិតខាងដោយស្មើភាព គោរពគ្នាទៅវិញទៅមក ក្នុងលក្ខណៈឯករាជ្យនិងអធិបតេយ្យពេញលេញ។

ការចូលរួមមិនប្រើប្រាស់ទំនិញនិងសេវាកម្មរបស់យួន ដូចជា មី កាហ្វេ បន្លែ សាច់ គ្រឿងឧបភោគបរិភោគ និងសេវាកម្មផ្សេងៗ ដូចជា ទូរស័ព្ទ(០៩៧) យន្តហោះ មន្ទីរពេទ្យ ។ល។ គឺជាការចូលរួមការពារកិត្តយសជាតិ និង ការពារប្រវត្តិសាស្ត្រខ្មែរយ៉ាងពិតប្រាកដ។ ជាមួយគ្នានេះក៏ជាការចូលរួមជួយលើកកម្ពស់ទំនិញនិងសេវាកម្មផ្សេងៗរបស់ជាតិខ្មែរយើងផងដែរ។

សហគមន៍ខ្មែរកម្ពុជាក្រោម និង សម្ព័ន្ធយុវជនខ្មែរ ដើម្បីប្រជាធិបតេយ្យ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបងប្អូនរួមឈាមទាំងអស់ ដែលបានចូលរួមឈប់ប្រើប្រាស់ទំនិញនិងសេវាកម្មផ្សេងៗរបស់យួន។

**ជយោ! ព្រះរាជាណាចក្រកម្ពុជា**
**រួមសាមគ្គីគ្នាឈប់ប្រើប្រាស់ទំនិញនិងសេវាកម្មយួន!**

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែតុលា ព.ស.២៥៥៨ គ.ស.២០១៤

**ថាច់ សេដ្ឋា**
ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម

ទីស្នាក់ការ: ផ្ទះលេខ ៧២ ផ្លូវលេខ ៤២៦A ភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី
ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា; ទូរស័ព្ទលេខ: (៨៥៥) ៧៨ ៨៩៨ ៨៨២ / ៩៣ ៤៧ ៤៧ ០៦
អាសយដ្ឋានអ៊ីមែល: thachsetha13@gmail.com, kkcpressoffice@yahoo.com
Website: khmerkromngo.org; Facebook: khmerkkcommunity

យើងរួមគ្នាសង្គ្រោះជាតិ និង ប្រវត្តិសាស្ត្រខ្មែរ

# បាត់សិទ្ធិ បាត់សេរីភាព បាត់អ្វីៗទាំងអស់

នៅមាតុភូមិកម្ពុជា និង កម្ពុជាក្រោម មិនមែននៅសហរដ្ឋអាមេរិក
ប្រទេសបារាំង កាណាដា អូស្ត្រាលី និងបណ្តាប្រទេសនានាឡើយ

## Loss of Rights, Freedom & All Aspects of Life

in Kampuchea (Cambodia) and Kampuchea Krom
Not in the United States, France, Canada, Australia & Other Countries

# ០៤ - ០៨ តុលា មហាបាតុកម្មបន្តទៀត

ដើម្បីការពារប្រវត្តិសាស្ត្រខ្មែរ និង កិត្តិយសប្រជាជាតិខ្មែរ

# OCT. 04 - 08

## Mass Demonstration Resuming

to Protect Khmer History and a National Honor of Cambodia

សហគមន៍ខ្មែរកម្ពុជាក្រោម KKC (The Khmer Kampuchea Krom Community) KhmerKromngo.org